**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Sep-2011, 10:36
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ស្នើសុំការអនុញ្ញាតដាក់ការឆ្លើយតប**
**និង**
**ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាលើការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន**

---

**សហមេធាវីការពារក្តី៖**

លោក អាង ឧត្តម
លោក Michael G. KARNAVAS

**ដាក់ជូន ៖**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **យ៉ា សុខន**
ចៅក្រម **យូរ ឧត្តរ៉ា**
ចៅក្រម Silvia CARTWRIGHT

---

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

## សំណើសុំការអនុញ្ញាតដាក់ការឆ្លើយតប

លោក អៀង សារី សូមដាក់សំណើនេះតាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“ក្រុមមេធាវីការពារក្តី”) ដើម្បីសុំការអនុញ្ញាតដាក់ការឆ្លើយតបទៅនឹង ចម្លើយតបរបស់សហព្រះរាជអាជ្ញាលើការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន (“ចម្លើយតប”)[១]។ ការឆ្លើយតបចាំបាច់ត្រូវធ្វើឡើងដោយហេតុថា ក.ស.ព **ក.** បកស្រាយដោយភាន់ច្រឡំលើលក្ខណៈ និងគោលបំណងនៃការជំទាស់របស់លោក អៀង សារី (“ការជំទាស់”)[២] **ខ.** បានបង្កើតឲ្យមានការយល់ឃើញខុសគ្នារវាង ក.ស.ព និងក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងច្បាប់ជាធរមាន និង **គ.** មានការភាន់ច្រឡំនៅពេលអះអាងថា ការជំទាស់របស់លោក អៀង សារី ទៅនឹងឯកសារជាក់លាក់មួយចំនួន ពុំមានមូលដ្ឋានសមរម្យ។ ម្យ៉ាងវិញទៀត សំណើសុំរបស់ កសព ឲ្យចេញសេចក្តីបង្គាប់លើការដាក់ការជំទាស់ ក្នុងរយៈពេលដែលច្បាប់អនុញ្ញាត និងក្នុងលក្ខណៈជាក់លាក់ គួរច្រានចោល ដោយសារតែវាជាការពុំចាំបាច់ ដើម្បីជាប្រយោជន៍ដល់ការសំចៃធនធានតុលាការ និងពន្លឿននីតិវិធី ក្រុមមេធាវីការពារក្តី សូមដាក់ការឆ្លើយតបរបស់ខ្លួន អមមកជាមួយនឹងសំណើនេះតែម្តង ។

## ការឆ្លើយតប

### ក. ក.ស.ព បកស្រាយដោយភាន់ច្រឡំលើលក្ខណៈ និងគោលបំណងនៃការជំទាស់

១. ក.ស.ព អះអាងថា ការជំទាស់ទាំងនេះ “គឺជាការពុំចាំបាច់ មានភាពផ្ទុយគ្នា និងស្រពិចស្រពិល”[៣]។ ជាការគួរឲ្យសោកស្តាយ ការអះអាងទាំងនេះ ជាការយល់ដោយភាន់ច្រឡំលើ

---

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាលើ “ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន” ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E114/1។

[២] ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយ ចំនួន ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E114។

[៣] ចម្លើយតប កថាខណ្ឌ ២។ ក.ស.ព បានតវ៉ាថា “ក្រុមមេធាវីការពារក្តី បានលើកឡើងការតវ៉ានាពេលមុនទៅនឹងភាពអាចទទួលយកបាននៃប្រភេទភស្តុតាងមួយចំនួន ដែលបានបញ្ចូលនៅក្នុងការជំទាស់ ហើយ “ការលើកឡើងបញ្ហាអង្គច្បាប់ដូចគ្នានៅក្នុងការដាក់ឯកសារច្បាប់ដោយឡែក...គឺជាការមិនគោរពការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងជាការដាក់បន្ទុកមិនចាំបាច់លើពេលវេលា និងធនធានរបស់ភាគី និងអង្គជំនុំជម្រះ”។ *ដូចខាងលើ* កថាខណ្ឌ ១៦-២១ ក.ស.ព អះអាងបន្ថែមទៀតថា ការជំទាស់ “មានភាពផ្ទុយគ្នាទាំងស្រុង”។ ក្រុមមេធាវីការពារក្តីតវ៉ាថា ខ្លួនគួរមានសិទ្ធិយកឯកសារណាមួយនៅក្នុងសំណុំរឿងមកសំអាងបាន ហើយ “ការដាក់ការជំទាស់ គឺខ្លួនលើកឡើងអំពីភាពមិនអាចទទួលយកបាននៃឯកសារបែបយ៉ាងយ៉ាងច្រើន”។ *ដូចខាងលើ* កថាខណ្ឌ ២៣។ ចំណុចចុងក្រោយ ក.ស.ព អះអាងថា ការជំទាស់ “មានលក្ខណៈស្រពិចស្រពិលមិនអាចទទួល

លក្ខណៈ និងគោលបំណងនៃការជំទាស់ ព្រមទាំងបញ្ជីឯកសាររបស់ភាគី។ ការជំទាស់ទាំងនេះ មិនមានជាការលើកឡើងច្រំដែលនោះទេ។ វាបង្កើតជាការដាក់ឯកសារលម្អិតបឋមរបស់ក្រុមមេធាវីការពារក្តី នៅមុនពេលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើការបកស្រាយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង (ហើយ ជាការពិតណាស់ ការចោទប្រកាន់ដោយត្រង់ៗជាប្រយោជន៍សម្រាប់ខ្លួនឯងនេះ ពុំមែនក្រុមមេធាវីការពារក្តីពុំបានដឹងនោះទេ ក្រោយពីខ្លួនបានពិចារណាលើសំណើលើកទី ៣ ស្នើសុំសេចក្តីណែនាំពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម)[៤]។ ការជំទាស់ទាំងនេះ មិនមានភាពផ្ទុយគ្នាឡើយ ហើយក៏មិនមានបំណងសុំឱ្យអង្គជំនុំជម្រះសាលាដំបូងឈានដល់ការដកឯកសារដ៏ "ច្រើនមហិមា" នៅក្នុងសំណុំរឿងនោះទេ។ ការជំទាស់ទាំងនេះ ក៏ពុំមែនជាសំណើសុំឱ្យទទួលស្គាល់បញ្ជីឯកសារទាំងនោះ ជាភស្តុតាងផងដែរ[៥] (ក្រុមមេធាវីការពារក្តីបានប្រកាន់យកវិធីសាស្ត្រជាក់លាក់រួមមួយ លើបញ្ជីឯកសារបឋមលើកទី៣ ៣ ដើម្បីអាចឱ្យខ្លួនមានលទ្ធភាពយកឯកសារទាំងនោះមកសំអាងនៅក្នុងពេលជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង)[៦]។ ការជំទាស់ទាំងនេះមិនមានលក្ខណៈស្រពិចស្រពិលនោះទេ ពីព្រោះវាបានវិភាគ

---

យកបាន" ពីព្រោះតែ ការជំទាស់ទាំងនេះខកខានមិនបានតវ៉ាលើភាពអាចទទួលយកបាននៃឯកសារជាក់លាក់។ *ដូចខាងលើ* កថាខណ្ឌ ២៤-២៦។

[៤] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្តល់សក្ខីកម្ម ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E101/1។ ចម្លើយតបទាំងស្រុងរបស់ក្រុមមេធាវីការពារក្តីទៅនឹងសំណើបន្ថែមនេះ នឹងដាក់ជូននៅក្នុងពេលសមស្រប។

[៥] ជាការពិត បញ្ជីឯកសារបឋមលើកទី ៣ របស់ក្រុមមេធាវីការពារក្តី លើកឡើងយ៉ាងច្បាស់ថា "ដោយសារតែមិនមែនជាឯកសារទាំងអស់នៅក្នុងបញ្ជីឯកសារបឋមលើកទីបីបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃសម្រាប់ភាពអាចទទួលយកបាននៅ អ.វ.ត.ក ទើបក្រុមមេធាវីការពារក្តីរក្សាសិទ្ធិជំទាស់នឹងឯកសារណា ដែលមាននៅក្នុងបញ្ជីដែលនឹងត្រូវដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" បញ្ជីឯកសារបឋមលើកទី ៣ របស់លោក អៀង សារី ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E9/25។

[៦] វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬ ស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬ ទទួលយកនូវភស្តុតាងថ្មី ដែល មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុ នៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬ ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។

យ៉ាងលម្អិតលើវិធានដែលយកមកអនុវត្តលើភាពអាចទទួលយកបាន ហើយយកវិធានទាំងនោះមកអនុវត្តលើប្រភេទឯកសារនានា នៅក្នុងសំណុំរឿងតែម្តង។ និយាយដោយសាមញ្ញទៅ ការជំទាស់ទាំងនេះ ផ្តល់ជាគម្រូសម្រាប់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការកំណត់របៀបរបបលើការពិនិត្យមើលឯកសារទាំងឡាយ មុនពេលទទួលយកមកធ្វើជាភស្តុតាង[៧] ហើយមានបំណងជ្រួយជ្រាមជ្រែងដល់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការបង្កើតវិធីសាស្ត្ររលូន និងស៊ីសង្វាក់គ្នាមួយនៅក្នុងការទទួលយកឯកសារ ព្រមទាំងផ្តល់នូវភាពជាក់លាក់តែប៉ុណ្ណោះ។

## ខ. កសព បង្កើតឲ្យមានការយល់ឃើញខុសគ្នាលើជំហររបស់ ក.ស.ព និងក្រុមមេធាវីការពារក្តី

២. នៅពេលមើលរំលងចំណុចសំខាន់ៗ ដែលជាមូលដ្ឋានរួមរបស់ភាគី[៨] ក.ស.ព បង្កើតឲ្យមានការយល់ឃើញខុសគ្នាលើជំហររបស់ ក.ស.ព និងក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងច្បាប់ជាធរមាន[៩]។ នៅពេល*ប្រតិកម្មលើបញ្ហាមិនចាំបាច់* មិនថា*ការវិភាគជាបឋម* ដែលបង្ហាញនូវ "យថាភាព" នៃឯកសារ គឺជាលក្ខណៈវិនិច្ឆ័យឯករាជ្យនៃភាពអាចទទួលយកបាន ឬ ជាធាតុនៃ

---

[៧] ការជំទាស់ទាំងនេះ ស្របតាមទម្លាប់ដាក់សេចក្តីសន្និដ្ឋាន ដែលបានអនុវត្តនៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ដែលភាគី ទម្លាប់ដាក់សេចក្តីសន្និដ្ឋានស្តីពីគោលការណ៍ណែនាំ ដែលត្រូវអនុវត្តលើភាពអាចទទួលយកបាននៃភស្តុតាង ហើយទម្លាប់ដាក់សេចក្តីសន្និដ្ឋាននេះឆ្លុះបញ្ចាំងនូវការប្រឹងប្រែងនានារបស់ក្រុមមេធាវីការពារក្តី នៅក្នុងការតំណាងលោក អៀង សារី ដោយយកចិត្តទុកដាក់។ *សូមមើល* ការជំទាស់ កំណត់សម្គាល់លេខ ២៥។

[៨] ជាឧទាហរណ៍ ពាក់ព័ន្ធនឹងច្បាប់ ភាគីមានមូលដ្ឋានរួមដូចគ្នា ពោលគឺ **ក.** វិធានផ្ទៃក្នុង អ.វ.ត.កស្តីពីភាពអាចទទួលយកបានមានភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ។ ចម្លើយតប កថាខណ្ឌ ៧។ **ខ.** វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ចែងថាភស្តុតាងត្រូវតែបំពេញទៅតាមបទដ្ឋានអប្បបរមានៃភាពជាប់ពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន។ *ដូចខាងលើ* កថាខណ្ឌ ៨។ **គ.** ភស្តុតាងពាក់ព័ន្ធត្រូវជាសម្ភារៈ*ដែលអាចឲ្យជឿពីដំបូង* បង្ហាញពីបញ្ហានានា និងទំនងជាបង្ហាញនូវជំហររបស់ភាគី។ *ដូចខាងលើ* កថាខណ្ឌ ៩។ **ឃ.** វិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុង រួមបញ្ចូលទាំងវិធាន "ភស្តុតាងប្រសើរបំផុត"។ *ដូចខាងលើ* កថាខណ្ឌ ១១។ **ង.** វិធាន ៨៧(៣) ក៏អនុញ្ញាតឲ្យដកចេញភស្តុតាងណាមួយ ដោយផ្អែកលើមូលដ្ឋានថា "ច្បាប់មិនអនុញ្ញាតឲ្យដាក់ភស្តុតាងបែបនេះ"។ *ដូចខាងលើ* កថាខណ្ឌ ១៣។ **ច.** ចម្លើយបានមកពីទារុណកម្ម ស្ថិតនៅក្រោមប្រភេទភស្តុតាង ដែល "ច្បាប់ពុំអនុញ្ញាត" ហើយវិធាន ២១(៣) នៃវិធានផ្ទៃក្នុង និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ហាមឃាត់ការទទួលយកចម្លើយទាំងនេះ។ *ដូចខាងលើ* កថាខណ្ឌ ១៤។ និង **ឆ.** ការវាយតម្លៃលើទម្ងន់នៃភស្តុតាង គឺជាការស៊ើបអង្កេតដោយឡែក ខុសពីភាពអាចទទួលយកបាន។ *ដូចខាងលើ* កថាខណ្ឌ ១៥។

[៩] *សូមមើល* ចម្លើយតប កថាខណ្ឌ ២ ដែល ក.ស.ព អះអាងថា ការជំទាស់ "ជាការមិនត្រឹមត្រូវតាមច្បាប់ទាក់ទងនឹងចំណុចជាក់លាក់"។

ភាពអាចទុកចិត្តបានមួយនោះ[១០] វាជាការគួរឲ្យសោកស្តាយ ដែល ក.ស.ព ខកខានមិនបានគិតគូរថា ភាគីបានឯកភាពគ្នាហើយថា យ៉ាងហោចណាស់ ត្រូវមានការបង្ហាញ*ជាបឋម* លើយថាភាពដើម្បីអាចឲ្យឯកសារទាំងឡាយទទួលយកបាន អនុលោមតាមវិធាន ៨៧(៣)(គ)នៃវិធានផ្ទៃក្នុង[១១]។

៣. ក្រុមមេធាវីការពារក្តីពុំដែលស្នើសុំឲ្យមាន "ការហាមឃាត់ដាច់ខាត" លើរបាយការណ៍ អត្ថបទ និងឯកសារនានា ដែលមិនបានបន្សល់ទុកពីសម័យនោះ ព្រមទាំងសក្ខីកម្មរបស់សាក្សី[១២] ដូច ក.ស.ព បានលើកឡើងនោះទេ[១៣]។ ក្រុមមេធាវីការពារក្តី គ្រាន់តែជំទាស់ទៅនឹងការយកសក្ខីកម្មមកបញ្ចូលជាភស្តុតាងតែប៉ុណ្ណោះ "ដោយសារ លោក អៀង សារី ពុំទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយនឹងសាក្សីនោះ"[១៤]។ ម្យ៉ាងវិញទៀត "តម្លៃជាភស្តុតាងនៃរបាយការណ៍ និងអត្ថបទសារព័ត៌មានមួយចំនួន អាចមានទម្ងន់ស្រាលជាងអានុភាពនៃភាពលម្អៀងរបស់វាទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធី"[១៥] ហេតុដូច្នេះ ឯកសារបែបនេះ មិនអាចទទួលយកបានឡើយ អនុលោមតាមវិធាន ៨៧(៣)(គ)នៃវិធានផ្ទៃក្នុង[១៦]។ ក្រុមមេធាវីការពារក្តីពុំជំទាស់ទេថា យុត្តិសាស្ត្រនៃសាលាក្តី *មិនអចិន្ត្រៃយ៍* ឆ្លុះបញ្ចាំង "អំពីការចង់ឲ្យមានការវាយតម្លៃជាភស្តុតាងនៃ

---

[១០] *ដូចខាងលើ* កថាខណ្ឌ ១០, ២៧-២៨។

[១១] *ដូចខាងលើ* កថាខណ្ឌ ១០-១១។ ការជំទាស់បានកត់សម្គាល់ថា "[ទោះបី]ជា[យថាភាព]នេះមិនមែនជាវិធានដែលចែងពីភាព ដែលអាចទទួលយកបានក៏ដោយ តែមានការរំពឹងទុកថា ភាគីដែលបានដាក់សំណើ (ដែលត្រូវបង្ហាញពីភាពដែលអាចជឿជាក់បាន) ត្រូវបង្ហាញនូវលក្ខណៈមួយចំនួន ដូចជាថាតើឯកសារនេះជាឯកសារប្រភេទអ្វី ហើយថាវាជាឯកសារពិតប្រាកដ ឬមិនពិតប្រាកដ មុនពេលដែលឯកសារនោះត្រូវបានទទួលយកមកធ្វើជាភស្តុតាង"។ ការជំទាស់ កថាខណ្ឌ ៦។

[១២] *សូមមើល* ចម្លើយតប កថាខណ្ឌ ៤៣។

[១៣] ក.ស.ព អះអាងថា "ការជំទាស់មានបំណងមិនព្រមទទួលរាល់ឯកសក្ខីកម្មទាំងអស់ ទោះបីជាសក្ខីកម្មរបស់បុគ្គល ដែលនឹងត្រូវផ្តល់សក្ខីកម្មផ្ទាល់មាត់នៅក្នុងពេលសវនាការក៏ដោយ"។ *ដូចខាងលើ* កថាខណ្ឌ ៥០ (គូសបញ្ជាក់បន្ថែម)។ ដូចគ្នានេះដែរ ក.ស.ព អះអាងថា ក្រុមមេធាវីការពារក្តីជំទាស់ទៅនឹងការទទួលយកគ្រប់ "របាយការណ៍ អត្ថបទ និងឯកសារ ដែលមិនបានបន្សល់ទុកពីសម័យនោះ"។ *ដូចខាងលើ* កថាខណ្ឌ ៤២, ៤៩។

[១៤] ការជំទាស់ កថាខណ្ឌ ២០។

[១៥] *ដូចខាងលើ* កថាខណ្ឌ ១៨ (គូសបញ្ជាក់បន្ថែម)។

[១៦] *ដូចខាងលើ* (គូសបញ្ជាក់បន្ថែម)។

ឯកសារជាក់លាក់នីមួយៗ ធៀបនឹងភាពលម្អៀងជាក់ស្តែងក្នុងកាលៈទេសៈពិសេសនានា”[១៧] ហើយដោយសារហេតុផលនេះមួយផ្នែកហើយ ទើបវាទុកសិទ្ធិយ៉ាងជាក់លាក់បន្តមកទល់បច្ចុប្បន្ន អនុញ្ញាត “ឲ្យលើកការជំទាស់នានា ទៅនឹងឯកសារជាក់លាក់ ទៅតាមករណីនីមួយៗ”[១៨]។

## គ) ក.ស.ព មានការភាន់ច្រឡំ នៅពេលអះអាងថា ការជំទាស់របស់មេធាវីការពារក្តីទៅនឹងប្រភេទឯកសារជាក់លាក់មួយចំនួន ពុំមានមូលដ្ឋានសមរម្យ

៤. ក.ស.ព អះអាងថា ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តីថា ឯកសារដែល ក.ស.ព ទទួលបានអាចមិនគួរឲ្យជឿជាក់បានទេ ដោយសារតែភាពលម្អៀងរបស់ស្ថាប័នទូទៅ “ពុំមានលក្ខណៈសមហេតុសមផល”[១៩]។ ជំនឿទុកចិត្តរបស់ ក.ស.ព ទៅលើភាពអព្យាក្រឹត្យនៃស្ថាប័នស៊ើបអង្កេតរបស់ អ.វ.ត.ក ហាក់ដូចជាមានលក្ខណៈចម្លែក និងផ្ទុយគ្នា យ៉ាងហោចណាស់នៅពេលយកទៅប្រៀបធៀបជាមួយជំហររបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានបំពាន “កាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន ក្នុងការបំពេញកិច្ចស៊ើបសួរឲ្យបានពេញលេញ និងមិនលម្អៀង” នៅក្នុងសំណុំរឿង ០០៣[២០]។

៥. ដោយសារឯកសារដែលបានតាក់តែង ឬ រៀបចំឡើងដោយបុគ្គលទាំងឡាយដែលមានទំនាក់ទំនងនឹង ក.ស.ព វាផ្ទុយទៅនឹងការអះអាងរបស់ ក.ស.ព ដែលថា “អង្គបុរេជំនុំជម្រះបានដោះស្រាយបញ្ហានេះរួចរាល់ហើយ”[២១] នោះការពិចារណាថាតើការស៊ើបអង្កេតគួរត្រូវបានធ្វើមោឃភាព ឬយ៉ាងណា ដោយកសារតែកំហុសនីតិវិធី [ដោយអនុលោមតាមវិធាន ៧៦(២)] គឺមានលក្ខណៈខុសគ្នាពីបញ្ហាថាតើឯកសារទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មិនគួរទទួលយកឬ

---

[១៧] ចម្លើយតប កថាខណ្ឌ ៤៤។

[១៨] ការជំទាស់ កថាខណ្ឌនៃសេចក្តីផ្តើម។

[១៩] ចម្លើយតប កថាខណ្ឌ ៣៣។

[២០] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹង “សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣” ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ D20/4/2.1 ផ្នែកទី ៥(គ)(២)។

[២១] ចម្លើយតប កថាខណ្ឌ ៣៧។ ក.ស.ព អះអាងថា “ក្រុមមេធាវីការពារក្តីស្នើសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ ដោយផ្អែកទៅលើការសន្មតថាមានភាពលំអៀងរបស់មន្ត្រីស៊ើបអង្កេតនៃ ក.ស.ច.ស ដែលក្នុងនោះធ្លាប់មានមន្ត្រីមួយរូបធ្លាប់បានបមពេញការងារឲ្យ ក.ស.ព”។

យ៉ាងណា [ដោយអនុលោមតាមវិធាន ៨៧(៣)]។ ឧទាហរណ៍ ទោះបីជាមានការពិចារណាថា បណ្ឌិត Craig Etcheson ពិតជាមានភាពសត្យានុម័ត និងមិនលម្អៀង នៅពេលដែលគាត់បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០១ និងថា "អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី" បដិសេធអ្នកជំនាញដោយសំអាងលើការជាប់ទាក់ទងរបស់អ្នកទាំងនោះជាមួយភាគីណាមួយក៏ដោយ[២២] ក៏វាមិនមែនមានន័យថា ការធ្វើឱ្យប៉ះពាល់ដល់ឯកសារទាំងអស់ដែល ក.ស.ព បានទទួល មិនជះឥទ្ធិពលដល់តម្លៃភស្តុតាងនៃបញ្ហា... អស់ដែល ក.ស.ព បានទទួល មិនជះឥទ្ធិពលដល់តម្លៃភវនីយហេតុនោះឡើយ។ ទាក់ទងនឹងបញ្ហានេះ ក្រុមមេធាវីការពារក្តីសូមដាក់បញ្ចូលជាសំអាងនូវទឡ្ហីករណ៍ដែលបានលើកឡើងទាក់នឹងអ្នកជំនាញ ដែលមានទំនាក់ទំនងនឹងភាគីណាមួយ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើសុំឱ្យចាត់តាំងអ្នកជំនាញបន្ថែម[២៣]។

៦. ក្រុមមេធាវីការពារក្តីមិនយល់ស្របទៅនឹងចេតនារបស់ ក.ស.ព ដើម្បីបន្ធូរបន្ថយការព្រួយបារម្ភរបស់ខ្លួនទាក់ទងនឹងភាពសត្យានុម័តនៃឯកសារ ដែលបានប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងកម្រោងស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ("CGP")។ ខណៈដែល ក.ស.ព អះអាងថា "ទាក់ទងទៅនឹង DC-Cam និង CGP មិនមានការលើកឡើងអំពីភាពលំអៀងទាក់ទង នឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលនោះ"[២៤] តាមពិតទៅ វាជាការផ្ទុយស្រឡះ។ ទាក់ទងនឹង DC-Cam លោក ឆាង យុក ដែលជានាយករបស់អង្គការនេះបានសរសេរថា "ភស្តុតាងដោយប្រយោល និងតាមរយៈសក្ខីកម្មរបស់សាក្សី អាចបញ្ជាក់ពីកម្រិតនៃប្រភពឯកសារដែលយកមកសំអាង ហើយ [លោក អៀង សារី និងលោក ខៀវ សំផន] <u>សមនឹងទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ</u>ចំពោះឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃបំផុតនៃរបប ប៉ុល ពត ហើយ"[២៥]។

---

[២២] *ដូចខាងលើ* កថាខណ្ឌ ៣៨។

[២៣] បណ្តឹងរបស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំតែងតាំងអ្នកជំនាញបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D140/4/1 កថាខណ្ឌ ២២ ដល់ ២៩។

[២៤] សំណើសុំ កថាខណ្ឌ ៣២។

[២៥] សៀវភៅនិពន្ធដោយ John D. Ciorciari និង យុក ឆាង។ *ការចងក្រងឯកសារស្តីពីឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុង* JAYA RAMJI និង BETH VAN SCHAAK, EDS., ការនាំខ្លួនខ្មែរក្រហមមកកាត់ទោស៖ ការផ្តន្ទាទោសអំពើហិង្សាដ៏ធំធេងនៅចំពោះមុខតុលាការកម្ពុជា ២២១, 285 (Edwin Mellen 2005) ។

ទាក់ទងនឹង CGP វិញ បណ្ឌិត Ben Kiernan ដែលនាយកស្ថាបនិករបស់គម្រោងនេះ បានសរសេរថា នៅមុនឆ្នាំ ១៩៩៦ "នួន ជា ឌុច អៀង សារី និង ខៀវ ធីរិទ្ធ មានសង្ឃឹមតិចតួចថា នឹងប្រឈមមុខទៅនឹងការចោទប្រកាន់តាមផ្លូវច្បាប់ ចំពោះការរំលោភច្បាប់អន្តរជាតិរបស់ខ្លួន កាលពីទសវត្សរ៍មុន"[២៦]។ ការអះអាងនេះហួសពីការងារជាប្រវត្តិសាស្ត្រ ដោយការរៀបចំអង្គហេតុនានា ក្នុងការស្វែងរកការទាមទារចង់បានជាអ្នកប្រាជ្ញ ហើយបានឆ្លុះបញ្ចាំងពីភាពលំអៀងរបស់អ្នកនិពន្ធទាំងនេះ ទាក់ទងទៅនឹងបញ្ហាច្បាប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីនេះ។

៧. ចំពោះឯកសារដែល "បានមកដោយអំពើទារុណកម្ម" ក.ស.ព "បានកត់សម្គាល់ថា" "នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកមកធ្វើជាភស្តុតាងនូវចំណារ នានាដែលសរសេរឡើងដោយជនជាប់ចោទ នៅលើចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម នៅគុក ស-២១"[២៧]។ វាជារឿងជាក់ស្តែងដែលមិនអាចប្រកែកបានថា ស្ថាប័នដែលឧបត្ថម្ភថវិកាអង្គការសហប្រជាជាតិត្រូវតែប្រកាន់ខ្ជាប់ទៅនឹងលិខិត និងស្មារតីនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម នៅពេលដែលស្ថាប័នទាំងនោះជាប់កាតព្វកិច្ច អោយគោរពទៅតាមនោះ។ ឯកសារដែល "បានមកដោយអំពើទារុណកម្មទាំងអស់" មិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះនោះទេ (លើកលែងតែប្រឆាំងនឹងជនណាម្នាក់ដែលទទួលរងការចោទប្រកាន់ថាបានធ្វើទារុណកម្ម ដើម្បីយកមកធ្វើជាភស្តុតាងថាចម្លើយសារភាពនោះពិតជាបានធ្វើឡើងមែន)។ នេះរួមទាំងចំណារទៅលើចម្លើយសារភាពនៅមន្ទីរ ស-២១ ទាក់ទងទៅនឹងអ្វីដែលក្រុមមេធាវីការពារក្តីបានយកមកធ្វើជាសម្អាងចំពោះទឡ្ហីករណ៍ ដែលបានលើកឡើងទាក់ទងនឹងឯកសារដែលមាននៅក្នុងសារណារបស់ អៀង សារី ប្រឆាំងការប្រើប្រាស់ឯកសារដែលបានមកដោយការធ្វើទារុណកម្ម[២៨]។

---

[២៦] សៀវភៅនិពន្ធដោយលោក BEN KIERNAN, របប ប៉ុល ពត៖ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា នៅក្រោមរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ (បោះពុម្ពលើកទី ៣ នៅសាកលវិទ្យាល័យយែល ឆ្នាំ ២០០៨ ទំព័រ ១៥។

[២៧] ចម្លើយតប ទំព័រ ៤០។

[២៨] សារណារបស់ អៀង សារី ប្រឆាំងការប្រើប្រាស់ឯកសារដែលបានមកដោយការធ្វើទារុណកម្មនាពេលសវនាការចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E33 កថាខណ្ឌ ២០ ដល់ ២១។

## ឃ. សំណើសុំឲ្យចេញសេចក្តីបង្គាប់លើការដាក់ការជំទាស់ ក្នុងរយៈពេលដែលអនុញ្ញាត និងក្នុងលក្ខណៈជាក់លាក់ គួរច្រានចោល ដោយសារតែវាជាការពុំចាំបាច់

៨. សំណើរបស់ ក.ស.ព ស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យ "បង្គាប់ដល់ភាគីថា រាល់ការជំទាស់ទៅនឹងភស្តុតាងដែលបានធ្វើឡើងនាពេលអនាគត គឺចាំបាច់ត្រូវតែដាក់ជូននៅក្នុងរយៈពេលដែលអនុញ្ញាត និងក្នុងលក្ខណៈជាក់លាក់គ្រប់គ្រាន់មួយ"[២៩] គឺជាការពុំចាំបាច់។ អង្គជំនុំជម្រះបានបង្គាប់រួចហើយថា ខ្លួននឹងសម្រេចលើភាពអាចទទួលយកបាននៃឯកសារជាក់លាក់ ទៅតាមករណីនីមួយៗ[៣០]។ ការចេញសេចក្តីបង្គាប់បន្ថែមទៀត ពុំមានភាពសមស្របនៅក្នុងពេលនេះ នៅពេលដែលភាគីមិនទាន់បានដឹងផងថាតើឯកសារណាមួយដែលភាគី ប្រាកដជា មានបំណងចង់បង្ហាញនៅក្នុងការជំនុំជម្រះ ដំណាក់កាលដំបូងនោះ[៣១] និងតាមរយៈសាក្សី និង/ឬ តារាងណាមួយ។

**អាស្រ័យហេតុនេះ** យោងទៅលើសំអាងហេតុទាំងអស់ដូចបានលើកឡើងនៅក្នុងសារណានេះ មេធាវីការពារក្តីរបស់លោក អៀង សារី សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ផ្តល់**ការអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីដាក់ការឆ្លើយតបនេះ។

ខ. បដិសេធចោល ចម្លើយតប

គ. តម្រូវឲ្យភាគីបង្ហាញអំពីយថាភាព ភាពអាចទុកចិត្តបាន និងភាពអាចមានភាពពាក់ព័ន្ធនៃឯកសារ ដែលខ្លួនដាក់ជូនឲ្យទទួលយកមកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២។ និង

ឃ. ច្រានចោលឯកសារទាំងឡាយណា ដែលមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យអប្បបរមា។

---

[២៩] ចម្លើយតប កថាខណ្ឌ ៤០។

[៣០] ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀងចំសវនាការនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ E74 ទំព័រទី ៣។

[៣១] បញ្ជីឯកសាររបស់ភាគីសម្រាប់ការជំនុំជម្រះក្នុងដំណាក់កាលដំបូង ដែលបានដាក់នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ មានគោលបំណងគ្រាន់តែចង់ផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវ "ការចង្អុលបង្ហាញពីដំបូង" បញ្ជាក់ប្រាប់ថាតើឯកសារណាខ្លះដែលភាគីមានបំណងចង់យកមកសំអាង "ដើម្បីអាចឲ្យអង្គភាពបកប្រែភាសា បញ្ជាក់អំពីស្ថានភាពនៃការបកប្រែឯកសារដែលភាគីពិចារណាថាជាឯកសារសំខាន់ និងដើម្បីអាចឲ្យអង្គជំនុំជម្រះ អាចកំណត់នូវការលំបាកនៅសេសសល់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន"។ *សូមមើល* អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើរជូនទៅគ្រប់ភាគីទាំងអស់ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសារណានេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២១** ខែ **មីនា** ឆ្នាំ **២០១១**

សហមេធាវីការពារក្តីរបស់លោក **អៀង សារី**

________________ ______________________

**អាង ឧត្តម** **Michael G. KARNAVAS**